# ជំនួយស្មារតី

## ស្តីពីកិច្ចសហប្រតិបត្តិការឆ្លាំកម្ពុជា-អាមេរិក ឆ្នាំ២០២៤

## សម្រាប់កិច្ចប្រជុំ SOMTC នៅទីក្រុងវៀងចន្ទន៍

ចាប់ពីថ្ងៃទី២៦-២៨ ខែមិថុនា ឆ្នាំ២០២៤

## I. អំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគី

– ថ្ងៃទី១១ ខែកក្កដា ឆ្នាំ ១៩៥០ ៖ បង្កើតទំនាក់ទំនងការទូត

– ឯកអគ្គរដ្ឋទូតអាម៉េរិកប្រចាំកម្ពុជា ៖ ឯកឧត្តម **Patrick Murphy**
*(ថ្វាយសារតាំងនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៩)*

– ឯកអគ្គរាជទូតកម្ពុជាប្រចាំសហរដ្ឋអាម៉េរិក៖ ឯកឧត្តម **កែវ ឈា**
*(ជូនសារតាំងនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២)*

## II. ឯកសារសហប្រតិបត្តិការ ( ក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ)

១- **«អនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសហរដ្ឋអាម៉េរិក ស្តីពីការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរ ដែលមានសេចក្តីសម្រេចបណ្តេញចេញចុងក្រោយពីសហរដ្ឋអាម៉េរិក»** ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣ នៅរាជធានីភ្នំពេញ។

២- **«អនុស្សរណៈរវាងស្ថានបេសកកម្មសហរដ្ឋអាម៉េរិកប្រចាំកម្ពុជា និងនគរបាលជាតិកម្ពុជា»** ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ នៅរាជធានីភ្នំពេញ រវាងអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា និងស្ថានទូតអាម៉េរិកប្រចាំកម្ពុជា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើសេវាសន្តិសុខរវាងប្រទេសទាំងពីរ។

៣- **«អនុស្សរណៈយោគយល់គ្នា រវាងនគរបាលជាតិកម្ពុជា និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និង FBI»** ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ នៅទីក្រុងវ៉ាស៊ីនតោន បម្រើឱ្យកិច្ចសហ-ប្រតិបត្តិការលើវិស័យនានា ដូចជា ឧក្រិដ្ឋកម្មប្រឆាំងនឹងកុមារ បទល្មើសបច្ចេកវិទ្យាឧក្រិដ្ឋកម្មហិរញ្ញវត្ថុ និងការជួយគាំពារសិទ្ធិរបស់ប្រជាពលរដ្ឋប្រទេសទាំងពីរផងដែរ។

៤- **«អនុស្សរណៈកិច្ចសហប្រតិបត្តិការរវាងនគរបាលជាតិកម្ពុជា ជាមួយ FBI»** ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ ស្តីពីកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរគ្នាទៅវិញទៅមកនូវព័ត៌មានអត្តសញ្ញាណ ស្នាមម្រាមដៃ សម្រាប់បម្រើឱ្យគោលបំណងយុត្តិធម៌ព្រហ្មទណ្ឌ។

៥- «**លិខិតថ្លែងបំណងរវាងនគរបាលជាតិកម្ពុជា និងផ្នែកអនុវត្តច្បាប់ គយ និងអន្តោប្រវេសន៍** (ICE)» នៃក្រសួងសន្តិសុខជាតិសហរដ្ឋអាម៉េរិក ដើម្បីស៊ើបអង្កេតការធ្វើអាជីវកម្មផ្លូវភេទលើកុមារ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១០។

➢ **សំគាល់៖** កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ អគ្គលេខាធិការដ្ឋាន អ.ស.ប បានអញ្ជើញ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** ចូលរួមក្នុងកម្មវិធី « The 4th United Nations Conference to Review Progress Made in the Implementation of Programme of Action to Prevent, Combat and Eradicate the Illicit Trade in Small Arms and Light Weapons in All Its Aspects and International Tracing Instrument (RevCon4)» ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៧-២៨ ខែមិថុនា ឆ្នាំ២០២៤ នៅទីក្រុងញូយ៉ក សហរដ្ឋអាមេរិក។ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** បានចាត់**ឯកឧត្តម ម៉ៅ ទិត្យារុណ** ភារធារីស្តីទី នៃស្ថានបេសកកម្មកម្ពុជា ប្រចាំអ.ស.ប ចូលរួមជាតំណាងដ៏ខ្ពង់ខ្ពស់។

## III. កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច

❖ **ទំនាក់ទំនងពាណិជ្ជកម្ម (ឯកតា ៖ លានដុល្លារអាម៉េរិក)**

| | ២០២១ | ២០២២ | ២០២៣ | ២០២៤ (ត្រីមាសទី១) |
|---|---|---|---|---|
| នាំចេញទៅ អាម៉េរិក | ៧.៤៨៦ | ៨.៩៦៩ | ៨.៨៩៧ | ១.៩៨៦ |
| នាំចូលពី អាម៉េរិក | ៣៣៦ | ៣១៣ | ២២៣ | ៥៧ |
| សរុប | ៧.៨២២ | ៩.២៨២ | ៨.៣៦៧ | ២.០៤៣ |

❖ **វិស័យទេសចរណ៍**

| ភ្ញៀវទេសចរណ៍ អាម៉េរិក មកកម្ពុជា | ២០២១ | ២០២២ | ២០២៣ | ២០២៤ (គិតត្រឹមខែមីនា) |
|---|---|---|---|---|
| | ៦.៥៣៥នាក់ | ៧៦.៦៧០នាក់ | ១៨៤.៨៧០នាក់ | ៦៦.៧៥២នាក់ |

## IV. កិច្ចសហប្រតិបត្តិការសន្តិសុខ (គិតពីឆ្នាំ២០២៣ ដល់ខែមេសា ឆ្នាំ២០២៤)

### ១- កិច្ចសហការជាមួយរដ្ឋបាលប្រឆាំងគ្រឿងញៀនអាម៉េរិក

- ផ្លាស់ប្តូរព័ត៌មាន និងបង្ក្រាបគ្រឿងញៀនចំនួន ០៦ ករណី៖
  - ចាប់ខ្លួន ៖ ១៧នាក់ (ចិនតៃវ៉ាន់៖ ១១នាក់, វៀតណាម ០៣នាក់, ទ្រីនីដា ០១នាក់, ថៃ ០១នាក់, បូលីវី ០១នាក់)

- រឹបអូសគ្រឿងញៀន ៖ ២.២៣៨គីឡូ ៨៩៨ក្រាម

២- **កិច្ចសហការបង្ក្រាបករណីរំលោភបំពានផ្លូវភេទកុមារ**

- ផ្លាស់ប្ដូរព័ត៌មាន និងបង្ក្រាបចំនួន ០៧ករណី ក្នុងនោះបានឆ្លើយតប ០៦ករណី និងកំពុងបន្តស្រាវជ្រាវ ០១ករណី។

៣- **កិច្ចសហការការពារក្រុមបេសកកម្មរុករកអដ្ឋិធាតុជនជាតិអាមេរិកបាត់ខ្លួន (០១ លើក)**

- ជីកនៅតំបន់កន្ទុយនាគ ខេត្តរតនគិរី (ថ្ងៃទី០៥ ខែកុម្ភៈ ដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៤)
- ជាលទ្ធផល រកឃើញ ២២បំណែក (ឆ្អឹងជាតិកាល់ស្យូម ១៩បំណែក)

## V. ស្ថានភាពពលរដ្ឋអាម៉េរិកនៅកម្ពុជា

❖ **ពលរដ្ឋអាម៉េរិកធ្វើដំណើរចេញ-ចូលប្រទេសកម្ពុជា (រយៈពេល ០៤ខែ នៃឆ្នាំ ២០២៤)**

- បានធ្វើដំណើរចូលសរុប ៨២,៩៤៨នាក់ កើន ១៩,៩២% បើធៀបនឹងរយៈពេលដដែលនៃឆ្នាំ២០២៣
- បានធ្វើដំណើរចេញសរុប ៨៤,៣១១នាក់ កើន ២០,២៨% បើធៀបនឹងរយៈពេលដដែលនៃឆ្នាំ២០២៣

❖ **ចំនួនទិដ្ឋាការដែលផ្តល់ឱ្យពលរដ្ឋអាម៉េរិក (រយៈពេល ០៤ខែ នៃឆ្នាំ ២០២៤)**

- បានផ្តល់ទិដ្ឋាការចូល ចំនួន ៣៨,២៨៤នាក់
- បានបន្តទិដ្ឋាការស្នាក់នៅ ចំនួន ៣,៤៩៥នាក់
- បានផ្តល់ទិដ្ឋាការចេញ ចំនួន ២៥០នាក់។

❖ **ពលរដ្ឋអាម៉េរិកប្រព្រឹត្តបទល្មើស/ស្លាប់/រងគ្រោះ (គិតត្រឹមខែឧសភា ឆ្នាំ២០២៤)**

- បទល្មើស ៖ ០២នាក់ (ឃាតកម្ម ០១នាក់ និងស្នាក់នៅខុសច្បាប់ ០១នាក់)
- ស្លាប់ ៖ ៤៨នាក់ (គាំងបេះដូង ២៥នាក់, ជំងឺ ១៥នាក់, គ្រោះថ្នាក់ចរាចរណ៍ ០១នាក់, អត្តឃាត ០៦នាក់ និងភ្លើងឆេះ ០១នាក់)
- រងគ្រោះ ៖ ០៣នាក់ (គ្រោះថ្នាក់ចរាចរណ៍ ០២នាក់ និងចោរលួចសម្ភារៈ ០១នាក់)

❖ **ពលរដ្ឋអាម៉េរិកជាប់ឃុំនៅកម្ពុជា (គិតត្រឹមថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤)**

- ពលរដ្ឋអាម៉េរិកចំនួន **១៩នាក់** កំពុងជាប់ឃុំនៅកម្ពុជា ក្នុងនោះ៖ ជនត្រូវចោទ **០៦នាក់** ជនជាប់ចោទ **០៣នាក់** ពិរុទ្ធជន **០៨នាក់** (ស្រី **០១នាក់**) និងទណ្ឌិតចំនួន **០៣នាក់**។

## VI. លទ្ធផលប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្ស

- ក្នុងត្រីមាសទី១ ឆ្នាំ២០២៤ បានបង្ក្រាបអំពើជួញដូរមនុស្សចំនួន ៤១ករណី ជនល្មើសចំនួន ៥០នាក់។
- ចាប់ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២៣ គណៈប្រតិភូអន្តរក្រសួងកម្ពុជា ដឹកនាំដោយ លោកជំទាវ កិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារីបានរៀបចំ «កិច្ចសន្ទនាអន្តរក្រសួងទ្វេភាគីស្តីពីការប្រឆាំងការជួញដូរមនុស្ស» ចំនួន **០៤ដង** ជាមួយប្រតិភូអាមេរិក ដឹកនាំដោយ ឯកឧត្តម W. Patrick Murphy។ (លើកចុងក្រោយនៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២៣)។

## III. លទ្ធផលប្រតិបត្តិការបង្ក្រាបគ្រឿងញៀន

- ក្នុងត្រីមាសទី១ ឆ្នាំ២០២៤ បានបង្ក្រាបគ្រឿងញៀនចំនួន **១៨១២ករណី** ឃាត់ខ្លួនបានមនុស្សចំនួន **៤៤៥១**នាក់ ស្មើនឹង **៤៨សញ្ជាតិ** ចាប់បានគ្រឿងញៀនសរុប **១តោន ៨៦៣គីឡូក្រាម ៦០៤**ក្រាម។

## VII. អំពីការពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល

❖ ***ទិន្នន័យអង្គការ-សមាគម/គណបក្សនយោបាយ/សហគមន៍ជនជាតិដើមភាគតិច (គិតត្រឹមខែមេសា ឆ្នាំ២០២៤)***

- សមាគម និងអង្គការមិនមែនរដ្ឋាភិបាលមានចំនួនសរុប **៦,៣៤៦** (សមាគមចំនួន **២,៧៩៦** អង្គការមិនមែនរដ្ឋាភិបាលចំនួន **៣,៥៥០**)។
- គណបក្សនយោបាយដែលបានចុះបញ្ជីសរុបចំនួន **៤៧** ក្នុងនោះ គណបក្សដែលបានបង្កើតថ្មីមានចំនួន ០២។
- សហគមន៍ជនជាតិដើមភាគតិចមានចំនួនសរុប **១៥៣**។

❖ ***ការធានាសិទ្ធិសេរីភាពអង្គការ-សមាគម***

- ដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពរបស់អង្គការសង្គមស៊ីវិល ក្រសួងមហាផ្ទៃបានណែនាំដល់រដ្ឋបាលរាជធានី-ខេត្ត (សេចក្តីណែនាំលេខ ០៤០ សជណ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ និងលិខិតលេខ ២០០៦ សជណ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨)៖
  - គាំទ្រ និងសម្របសម្រួលដល់ការអនុវត្តសិទ្ធសេរីភាព របស់អង្គការសង្គមស៊ីវិល ដោយរាល់ការអនុវត្តសកម្មភាពរបស់អង្គការ-សមាគមពុំចាំបាច់ត្រូវជូនដំណឹងដល់អាជ្ញាធរមូលដ្ឋាននោះឡើយ

- រដ្ឋបាលរាជធានី-ខេត្តត្រូវរៀបចំវេទិកាពិគ្រោះយោបល់ ជាមួយអង្គការសង្គមស៊ីវិល ដែលធ្វើសកម្មភាពក្នុងដែន សមត្ថកិច្ចរបស់ខ្លួនឱ្យបានទៀងទាត់រៀងរាល់ឆមាស ឬ តាមការចាំបាច់។

❖ ***ការរៀបចំវេទិការដ្ឋាភិបាល និងសង្គមស៊ីវិល***

– ទន្ទឹមនេះ រាជរដ្ឋាភិបាលបានសម្រេចឱ្យក្រសួងមហាផ្ទៃ រៀបចំ «វេទិកាស្ដីពីភាពជាដៃគូរវាង សង្គមស៊ីវិល និងរាជរដ្ឋាភិបាល» និងបង្កើត «ក្រុមការងាររបស់រាជរដ្ឋាភិបាលដើម្បីដោះស្រាយ សំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិល» ដើម្បីសម្រប សម្រួលសំណើ និងសំណូមពរ របស់អង្គការសង្គមស៊ីវិល។

- «**វេទិកាស្ដីពីភាពជាដៃគូរវាងសង្គមស៊ីវិល និងរាជរដ្ឋាភិបាល**» បានរៀបចំឡើងចំនួន **០៥លើក** (លើកចុងក្រោយថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣)។
- «**ក្រុមការងាររបស់រាជរដ្ឋាភិបាលដើម្បីដោះស្រាយសំណើ និងសំណូមពររបស់អង្គការ សង្គមស៊ីវិល**» បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រុមអង្គការសង្គមស៊ីវិលបាន (ក្នុងនោះរួមមានតំណាងមកពី OHCHR ចូលរួមសង្កេតការណ៍ផងដែរ) ចំនួន **០៦លើក** (លើកចុងក្រោយនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០) លើសំណើសុំធ្វើវិសោធនកម្ម ច្បាប់ LANGO ចំនួន **១៦មាត្រា** ដែលស្នើដោយអង្គការសង្គមស៊ីវិល ។
  - កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ ក្រុមការងារ បានធ្វើការជួបពិភាក្សាជំណាក់កាល ទី២ ជាមួយតំណាង អង្គការសង្គមស៊ីវិល ដោយបានឯកភាពគ្នាលើមាត្រា ចំនួន ០៩ ហើយមាត្រាចំនួន ០៧ទៀត ត្រូវបានតំណាង អង្គការសង្គមស៊ីវិលស្នើសុំពិភាក្សាផ្ទៃក្នុង ឡើងវិញ។ មកដល់បច្ចុប្បន្ននេះ តំណាងអង្គការសង្គមស៊ីវិលមិនទាន់ផ្ដល់ការឆ្លើយតប ណាមួយមកវិញទេ។

## IV. ចំណុចដែលភាគីអាមេរិកអាចលើកឡើង

❖ ***សំណើពន្យារសុពលភាពទិដ្ឋាការពលរដ្ឋអាមេរិកស្នាក់នៅកម្ពុជា***

– នៅក្នុងជំនួបសម្ដែងការគួរសម កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ឯកឧត្តម Patrick Murphy បានស្នើសុំភាគីកម្ពុជាពិនិត្យលទ្ធភាពពន្យារសុពលភាពទិដ្ឋាការចំពោះពលរដ្ឋ អាមេរិក ដើម្បីអាចធ្វើដំណើរចូលប្រទេសកម្ពុជាបានច្រើនដង និងស្នាក់នៅប្រទេសកម្ពុជាបាន រយៈពេលយូរ (លើសពី ១ខែ) ហើយប្រសិនបើភាគីកម្ពុជាឯកភាព ភាគីអាមេរិកនឹងអនុវត្ត គោលការណ៍បដិការចំពោះពលរដ្ឋកម្ពុជាដែលធ្វើដំណើរចូលសហរដ្ឋអាមេរិកដែរ។

- យោងចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤ សម្តេចបានណែនាំជាគោលការណ៍គួររក្សាស្ថានភាពដូចបច្ចុប្បន្ន ដោយផ្អែកលើគោលការណ៍សង្គតិភាព។

❖ **ការចាប់ខ្លួនលោក ស៊ុន ចន្ធី ប្រធានគណបក្សកម្លាំងជាតិ**

- លោក ស៊ុន ចន្ធី ប្រធានគណបក្សកម្លាំងជាតិ ត្រូវបានកម្លាំងនគរបាលរាជធានីភ្នំពេញ បានចាប់ខ្លួននៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ អនុវត្តតាមដីកាបញ្ជាឱ្យចូលខ្លួនរបស់អយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ ពាក់ព័ន្ធ «ការញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម» ដោយអ្នកនាំពាក្យក្រសួងយុត្តិធម៌បានលើកឡើងថា «បុគ្គលរូបនេះបានផ្សព្វផ្សាយព័ត៌មានលើបណ្តាញសង្គម ដោយបានទម្លាក់កំហុសដោយអសុទ្ធចិត្តទៅលើរាជរដ្ឋាភិបាលលើការចែកប័ណ្ណក្រីក្រជូនប្រជាពលរដ្ឋថាមានការលម្អៀង និងរើសអើង ព្រមទាំងបានមូលបង្កាច់អំពីការអភិវឌ្ឍប្រទេសរបស់រាជរដ្ឋាភិបាល ក្នុងចេតនាញុះញង់បំភ្លៃព័ត៌មាន នាំឱ្យប្រជាពលរដ្ឋមានការយល់ច្រឡំ ដែលបង្កភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈ»។
- នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៤ ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចឃុំខ្លួន លោក ស៊ុន ចន្ធី នៅមណ្ឌលអប់រំកែប្រែទី៤ (ម៤) នៅក្នុងខេត្តពោធិ៍សាត់។

❖ **ប្រតិកម្មរបស់សហរដ្ឋអាមេរិកចំពោះព្រែកជីកហ្វូណនតេជោ**

- នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៤ លោក Wesley Holzer អ្នកនាំពាក្យស្ថានទូតអាមេរិកប្រចាំកម្ពុជា បានប្រាប់ទៅសារព័ត៌មាន VOA ខ្មែរ តាមអ៊ីមែលថា៖
    - «ប្រជាជនកម្ពុជា រួមជាមួយនឹងប្រជាជននៅប្រទេសជិតខាង និងនៅក្នុងតំបន់ និងទទួលបានអត្ថប្រយោជន៍ពីតម្លាភាពលើកិច្ចការសំខាន់ៗណាមួយ ដែលមានសក្តានុពលសម្រាប់ការគ្រប់គ្រងទឹកក្នុងតំបន់ និរន្តរភាពកសិកម្ម និងសន្តិសុខ»។
    - «សហរដ្ឋអាមេរិក ជំរុញឱ្យអាជ្ញាធរកម្ពុជាសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការទន្លេមេគង្គ ដើម្បីផ្តល់ព័ត៌មានលម្អិតបន្ថែមអំពីគម្រោង និងចូលរួមឱ្យបានពេញលេញក្នុងការសិក្សាអំពីផលប៉ះពាល់បរិស្ថាន ដើម្បីជួយគណៈកម្មការទន្លេមេគង្គ និងប្រទេសជាសមាជិកយល់ឱ្យបានពេញលេញ វាយតម្លៃ និងរៀបចំលើផលប៉ះពាល់ដែលអាចកើតមានពីគម្រោង»។

❖ លោក Jason G. Tower ជាប្រតិភូមកពីស្ថាប័នស្រាវជ្រាវ បានដាក់ឈ្មោះប្រទេសកម្ពុជា ឡាវ និងប្រទេសមីយ៉ាន់ម៉ា ជាប្រភព និងកន្លែងផ្តល់កំណើតដល់ក្រុមឆបោកតាមប្រព័ន្ធអនឡាញ (Online scams/Fraud)។

# ប្រវត្តិរូបសង្ខេប

## Brandon P. Yoder

### អនុប្រធាននាយកដ្ឋានប្រឆាំងគ្រឿងញៀន

### និងការអនុវត្តច្បាប់អន្តរជាតិ



## I. ប្រវត្តិការសិក្សា

- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសេវាការបរទេសមកពីសាកលវិទ្យាល័យ Georgetown University
- បរិញ្ញាបត្រមកពីសាកលវិទ្យាល័យ Hopkins University

## II. បទពិសោធន៍ការងារ

- បច្ចុប្បន្ន ជាអនុប្រធាននាយកដ្ឋានប្រឆាំងគ្រឿងញៀន និងការអនុវត្តច្បាប់អន្តរជាតិ (INL) ។ លោក Brandon ជាអ្នកគ្រប់គ្រងកម្មវិធី INL ដែលមានទឹកប្រាក់ចំនួនជាង 2 ពាន់លានដុល្លារនៅទូទាំងទ្វីបអឺរ៉ុប និងអាស៊ី សម្រាប់គម្រោងនានាដូចជា ពង្រឹងនីតិរដ្ឋ ការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន អំពើពុករលួយ ឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត ការជួញដូរគ្រឿងញៀន សត្វព្រៃ និងធនធានធម្មជាតិ ជាដើម។
- លោក Brandon ធ្លាប់ជាមន្ត្រីជំនាញជាន់ខ្ពស់ នៃគណៈកម្មាធិការទំនាក់ទំនងព្រឹទ្ធសភាបរទេស (SFRC) មុនពេលចូលរួមជាមួយរដ្ឋាភិបាល
- លោក Brandon ជាអ្នកតាក់តែងសេចក្តីព្រាងច្បាប់ និងដឹកនាំការចរចាទ្វេភាគីលើច្បាប់ជាច្រើនដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរថ្នាំប្រភេទ ហ្វង់តានីល(fentanyl) ខុសច្បាប់ និងជាអ្នកផ្សព្វផ្សាយគោលនយោបាយរបស់សហរដ្ឋអាមេរិកឆ្ពោះទៅប្រទេស អេក្វាឌ័រ ហៃទី នីហ្គារាហ្គ័រ និងវីណេស៊ូអេឡា
- លោក Brandon ធ្លាប់ធ្វើជាមន្ត្រីនៅអង្គការ National Endowment for Democracy-NED ។ នៅទីនោះគាត់បានគ្រប់គ្រងកម្មវិធីជំរុញអភិបាលកិច្ចតាមបែបលទ្ធិប្រជាធិបតេយ្យ សិទ្ធមនុស្ស និងការចូលរួមក្នុងឆាកនយោបាយ ទីនោះហើយដែលគាត់បានចាប់ផ្តើមការងារនៅក្នុងនាយកដ្ឋានកិច្ចការអឌ្ឍគោលខាងលិច នៃក្រសួងការបរទេស។